# ព្រះរាជក្រឹត្យ

នស/រកត/០៣២៥/ ៣៤០

## យើង

## ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០២០/១០៧៣ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៤/១០២៦ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលព្រះរាជក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីការគ្រប់គ្រងនិងការបើកផ្ដល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** បញ្ចប់តំណែងប្រធាន អនុប្រធាន និងសមាជិក នៃគណៈប្រឹក្សាយោបល់វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ របស់ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលត្រូវបានតែងតាំងតាមព្រះរាជក្រឹត្យលេខ នស/រកត/១២២០/១៣០៦ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២០។

**មាត្រា២ :** តែងតាំងនិងផ្តល់ឋានៈដល់ឥស្សរជននិងបញ្ញវន្ត ឱ្យបំពេញមុខងារជាប្រធាន អនុប្រធាន និងសមាជិក នៃគណៈប្រឹក្សាយោបល់វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ របស់ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ចំនួន២០រូប ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ឆែម គានរិទ្ធី** | ប្រធាន | |
| ២- | ឯកឧត្តម **ហ៊ីល សៀងហេង** | អនុប្រធាន | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៣- | ឯកឧត្តម **ឡឹម តារា** | សមាជិក | |
| ៤- | លោកជំទាវ **ជា រដ្ឋា** | សមាជិកា | |
| ៥- | លោកជំទាវ **ត្រី ណាល់លីស** | សមាជិកា | |
| ៦- | ឯកឧត្តម **ច័ន្ទ សុផល** | សមាជិក | |
| ៧- | ឯកឧត្តម **ឡេង គីរម្យ** | សមាជិក | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៨- | ឯកឧត្តម **ឃៀង សុធី** | សមាជិក | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៩- | ឯកឧត្តម **ហុង វ៉ាដា** | សមាជិក | |
| ១០- | ឯកឧត្តម **ស៊ុំ សត្ថា** | សមាជិក | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ១១- | ឯកឧត្តម **ផន គន្ធា** | សមាជិក | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ១២- | ឯកឧត្តម **ឈុន តូរី** | សមាជិក | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ១៣- | ឯកឧត្តម **ស្រ៊ីច ថារិទ្ធ** | សមាជិក | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ១៤- | ឯកឧត្តម **មិត្ត ហាសិកា** | សមាជិក | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ១៥- | ឯកឧត្តម **ចាយ សេងថា** | សមាជិក | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ១៦- | ឯកឧត្តម **ទីរៈ ខួតជា** | សមាជិក | មានឋានៈស្មើ អគ្គនាយក |
| ១៧- | ឯកឧត្តម **ឃឹម ប្រសិទ្ធីឬទ្ធិ** | សមាជិក | មានឋានៈស្មើ អគ្គនាយក |
| ១៨- | ឯកឧត្តម **ស៊ុំ វាសនា** | សមាជិក | មានឋានៈស្មើ អគ្គនាយក |
| ១៩- | ឯកឧត្តម **ចាន់ សារិន្ទ** | សមាជិក | មានឋានៈស្មើ អគ្គនាយក |
| ២០- | ឯកឧត្តម **ស្រ៊ុន សុវិឡា** | សមាជិក | មានឋានៈស្មើ អគ្គនាយក។ |

**មាត្រា៣ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០២៥

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

រ.ស.ល. ២៥០៣.០៣២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**វង្សី វិស្សុត**